ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

លេខ......២០..............អ.ន.ក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ និងលើកវិធានការបញ្ចៀសសំណល់សារធាតុ Tricyclazole នៅក្នុងអង្ករ

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម**

- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូឋានក្សេត្រសាស្ត្រ និងកែលំអរដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ១០៩ ប្រក.កសក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍កសិកម្ម ក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- យោងតាមការចាំបាច់របស់អគ្គនាយកដ្ឋានកសិកម្ម

## សម្រេច

**ប្រការ១៖** ត្រូវបានបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ និងលើកវិធានការបញ្ចៀស សំណល់សារធាតុ Tricyclazole នៅក្នុងអង្ករ ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១.បណ្ឌិត កែ មុន្នីវុធ | ប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ | ប្រធាន |
| ២.លោក ង៉ិន ឆាយ | ប្រធាននាយកដ្ឋានដំណាំស្រូវ | អនុប្រធាន |
| ៣.លោក នី វុទ្ធី | អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ | សមាជិក |

អាសយដ្ឋានលេខៈ ៥៤ប/៤៩អ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខៈ (០២៣) ៨៨៣ ៤២៧ ទូរសារលេខៈ (០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh, Cambodia, Phone : (023) 883 427, Fax : (023) 883 427

ភូតតាមអនាម័យ

| | | |
|---|---|---|
| ៤.លោក ជុំ ជ័យឥរិទ្ធ | អនុប្រធាននាយកដ្ឋានដំណាំស្រូវ | សមាជិក |
| ៥.លោក កង សារ៉េត | ប្រធានការិយាល័យការពារដំណាំ | សមាជិក |
| ៦.លោក លន សុជាតា | ប្រធានការិយាល័យនៃមន្ទីរពិសោធន៍ជាតិកសិកម្ម | សមាជិក |
| ៧. ជឹម ចាន់ណា | មន្ត្រីនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ | លេខាធិការ |

**ប្រការ២៖** ក្រុមការងារខាងលើមានភារកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មាន ទិន្នន័យ លើកវិធានការបញ្ចៀសសំណល់សារធាតុ Tricyclazole នៅក្នុងអង្ករ។

**ប្រការ៣៖** សេចក្តីសម្រេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**

**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ហ៊ាន វណ្ណហាន**

ចម្លងជូន៖

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋាននីតិកម្មកសិកម្ម
- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទ អគ្គនាយកដ្ឋានកសិកម្ម
  "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ